**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០០៩.....សហវ.......

ថ្ងៃព្រហស្បតិ៍ ៥រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

# សារាចរណែនាំ

## ស្តីពី

## វិធានការបើកប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងចំណាយកិច្ចដំណើរការរដ្ឋបាលនៃឃុំ សង្កាត់បង្កើតថ្មី, ប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ កើនចំនួនសមាជិកក្នុងអាណត្តិទី៥ និងប្រាក់ឧបត្ថម្ភប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលបង្កើតថ្មីនៅឃុំចំនួន ០៤ ក្នុងខេត្តកំពង់ចាម

**យោង** - អនុក្រឹត្យលេខ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥

- អនុក្រឹត្យលេខ១៥០ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំយាយម៉ៅពេជ្រនិល នៃស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
- អនុក្រឹត្យលេខ១៥១ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំភ្នំក្រាំងដីមាស នៃស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- អនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំអូរកណ្តៀរសែនជ័យ នៃស្រុកសំបូរ ខេត្តក្រចេះ
- អនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំបួរិល នៃស្រុកបវេល ខេត្តបាត់ដំបង
- អនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតសង្កាត់អូរជ្រៅ នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- អនុក្រឹត្យលេខ១៥៧អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតសង្កាត់អូរឬស្សី នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- ស្មារតីអង្គប្រជុំថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ រវាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ។

ដើម្បីមានមូលដ្ឋានអនុវត្តលើការបើកប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ និងចំណាយកិច្ចដំណើរការរដ្ឋបាលនៃឃុំ សង្កាត់បង្កើតថ្មី, ប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ កើនចំនួនសមាជិកក្នុងអាណត្តិទី៥ និងប្រាក់ឧបត្ថម្ភប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលបង្កើតថ្មីនៅឃុំចំនួន ០៤ ក្នុងខេត្តកំពង់ចាម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសារាចរណែនាំមានខ្លឹមសារដូចខាងក្រោម÷

**១.<u>ចំណាយសម្រាប់ឃុំ សង្កាត់ បង្កើតថ្មី ឆ្នាំ២០២២</u>**

ក- ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ បង្កើតថ្មីទាំង០៦ (ប្រាំមួយ) និងចំណាយដំណើរការរដ្ឋបាល ចាប់ពីខែកក្កដា ដល់ ខែធ្នូ ឆ្នាំ២០២២ ចំនួន ០៦ (ប្រាំមួយ) ខែ ត្រូវធានារ៉ាប់រងដោយសមតុល្យរបស់គណនីមូលនិធិឃុំ សង្កាត់ លេខ៤៤០៩ នៅអគ្គនាយកដ្ឋានរតនាគារជាតិ។ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ និងចំណាយដំណើរការរដ្ឋបាលមានភ្ជាប់ជូនក្នុងតារាងឧបសម្ព័ន្ធទី១។

ខ- ការបើកប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ និងអនុវត្តនីតិវិធីហិរញ្ញវត្ថុជាធរមាន។ រីឯការចំណាយថវិកាសម្រាប់កិច្ចដំណើរការរដ្ឋបាលត្រូវអនុវត្តតាមនីតិវិធីបុរេប្រទាន។ រដ្ឋបាលឃុំ សង្កាត់ថ្មីទាំង៦ អាចស្នើសុំបុរេប្រទានថវិកាសម្រាប់កិច្ចដំណើរការរដ្ឋបាលត្រីមាសទី៣ និងត្រីមាសទី៤ ពីរតនាគារខេត្តពាក់ព័ន្ធ។ ក្រោយពីការចំណាយ រដ្ឋបាលឃុំ សង្កាត់ត្រូវបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់បុរេប្រទានឱ្យបានមុនដំណាច់ឆ្នាំ២០២២។

គ- រដ្ឋបាលឃុំ សង្កាត់ថ្មី ពុំចាំបាច់រៀបចំគម្រោងថវិកាសម្រាប់ចំណាយនៅឆមាសទី២ ឆ្នាំ២០២២ ទេ។ គណនេយ្យករឃុំ សង្កាត់ត្រូវកាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ចំណូល ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ដែលពាក់ព័ន្ធ នៅឆមាសទី២ ឆ្នាំ២០២២។

ឃ- ប្រាក់ឧបត្ថម្ភរបស់ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលបានផ្ទេរពីឃុំ សង្កាត់ចាស់ទៅរដ្ឋបាលឃុំ សង្កាត់បង្កើតថ្មីត្រូវបន្តការបើកប្រាក់ឧបត្ថម្ភ នៅរដ្ឋបាលឃុំ សង្កាត់ចាស់រហូតដល់ដំណាច់ឆ្នាំ២០២២។

ង- រដ្ឋបាលឃុំ សង្កាត់បង្កើតថ្មី ហើយពុំមានអគាររដ្ឋបាលសម្រាប់បម្រើការងារ រដ្ឋបាលខេត្តសាមី ត្រូវជួយសម្របសម្រួល និងដោះស្រាយរកទីកន្លែង ឬជួលទីតាំងណាមួយសមរម្យជូនដល់រដ្ឋបាលឃុំ សង្កាត់ សម្រាប់បម្រើការងារ។ រីឯការចំណាយលើថ្លៃឈ្នួលទីតាំងនោះជាបន្ទុកចំណាយថវិកា របស់រដ្ឋបាលខេត្តសាមី។

ច- រដ្ឋបាលក្រុង ស្រុកសាមីត្រូវផ្តល់ការគាំទ្រ និងជំនួយបច្ចេកទេស ដល់រដ្ឋបាលឃុំ សង្កាត់បង្កើតថ្មី។ ក្នុងករណីរដ្ឋបាលឃុំ សង្កាត់បង្កើតថ្មីពុំមានមន្ត្រី សម្រាប់ជួយការងារហិរញ្ញវត្ថុ រដ្ឋបាលក្រុង ស្រុកសាមីត្រូវចាត់បញ្ជូនមន្ត្រីឱ្យទៅជួយការងារហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ថ្មីនោះជាបណ្តោះអាសន្ន រហូតដល់ពេលមានស្មៀនឃុំ សង្កាត់ ឬជំនួយការហិរញ្ញវត្ថុ។

**២. <u>ប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ កើនចំនួនសមាជិកក្នុងអាណត្តិទី៥</u>**

ប្រាក់ឧបត្ថម្ភប្រចាំខែក្រុមប្រឹក្សាថ្មី នៃឃុំ សង្កាត់ បង្កើនចំនួនក្រុមប្រឹក្សា នៅក្នុងអាណត្តិទី៥ ត្រូវបានធានារ៉ាប់រងដោយកញ្ចប់ថវិការបស់រដ្ឋបាលឃុំ សង្កាត់ចាស់ ដោយធ្វើការកែតម្រូវគម្រោងថវិកាឆ្នាំ២០២២ ឡើងវិញតាមនីតិវិធីនិយ័តកម្មថវិកាពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) ទៅគណនី អនុគណនីដែលត្រូវចំណាយជាក់ស្តែង។

៣- <u>ប្រាក់ឧបត្ថម្ភប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលបង្កើតថ្មីនៅឃុំចំនួន ០៤ ក្នុងខេត្ត កំពង់ចាម</u>

ប្រាក់ឧបត្ថម្ភរបស់ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ដែលបង្កើតថ្មីនៅឃុំចំនួន ០៤ ក្នុងខេត្តកំពង់ចាមត្រូវធានាដោយសមតុល្យគណនីមូលនិធិឃុំ សង្កាត់ ដែលបានពីការបែងចែកចំនួន ០,៥០ ភាគរយ នៃឧបត្ថម្ភធនរបស់ឃុំ សង្កាត់ទូទាំងប្រទេស សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២។

ដើម្បីឱ្យដំណើរការបើកប្រាក់ឧបត្ថម្ភជូនប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មី នៃឃុំទាំង០៤ របស់ខេត្តកំពង់ចាមបានឆាប់រហ័ស ម្ចាស់គណនីមូលនិធិឃុំ សង្កាត់អាចស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់បុរេប្រទានដោយបន្ថែមសមតុល្យគណនីមូលនិធិឃុំ សង្កាត់ រួចរៀបចំឯកសារផ្ទេរវិភាជន៍ថវិកាទៅគណនីប្រាក់បញ្ញើរបស់ឃុំទាំង០៤ នៅរតនាគារខេត្តកំពង់ចាម។

នៅពេលទទួលបានអាណត្តិបើកប្រាក់ ផ្តល់ឧបត្ថម្ភធនសម្រាប់ត្រីមាសទី៤ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវជម្រះចំនួនទឹកប្រាក់បុរេប្រទានដែលបានផ្តល់ (សម្រាប់ប្រាក់ឧបត្ថម្ភភូមិនៃឃុំទាំង០៤ នៅខេត្តកំពង់ចាម) ដោយកាត់ពីសមតុល្យគណនីមូលនិធិឃុំ សង្កាត់។

ប្រាក់ឧបត្ថម្ភរបស់ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិមានភ្ជាប់ជូនក្នុងតារាងឧបសម្ព័ន្ធទី២។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត លោក លោកស្រីអភិបាល នៃគណៈអភិបាលក្រុង ស្រុក និងលោក លោកស្រីមេឃុំ ចៅសង្កាត់ពាក់ព័ន្ធ អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន</u>
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានថវិកា
"ដើម្បីសហការអនុវត្ត"
- រដ្ឋបាលក្រុង ស្រុកសាមី
- រដ្ឋបាលឃុំ សង្កាត់សាមី
-ឯកសារ-កាលប្បវត្តិ

តារាងឧបសម្ព័ន្ធទី១ភ្ជាប់តាមសារាចរណែនាំលេខ ០០៩ សហវ ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០២២

ឯកតា: លានរៀល

| តារាងទិន្នន័យចំណាយរដ្ឋបាល និងប្រាក់ឧបត្ថម្ភជូនឃុំ សង្កាត់ថ្មីចំនួន៦<br>ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២២ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| លេខកូដ ឃុំ សង្កាត់ | ខេត្ត | ក្រុង ស្រុក | ឃុំ សង្កាត់ | ក្រុមប្រឹក្សា | ចំនួនភូមិ | រដ្ឋបាល | ប្រាក់ឧបត្ថម្ភ | សរុប |
| 011004 | បន្ទាយមានជ័យ | ប៉ោយប៉ែត | អូរជ្រៅ | 11 | 7 | 8.72 | 54.13 | 62.85 |
| 011005 | បន្ទាយមានជ័យ | ប៉ោយប៉ែត | អូរបួស្សី | 7 | 5 | 6.42 | 35.69 | 42.11 |
| 020409 | បាត់ដំបង | បវេល | បូរិល | 9 | 9 | 7.57 | 44.91 | 52.48 |
| 040614 | កំពង់ឆ្នាំង | រលាប្អៀរ | ភ្នំក្រាំងដីមាស | 5 | 8 | 5.26 | 26.47 | 31.73 |
| 050614 | កំពង់ស្ពឺ | ភ្នំស្រួច | យាយម៉ៅពេជ្រនិល | 9 | 9 | 7.57 | 44.91 | 52.48 |
| 100411 | ក្រចេះ | សំបូរ | អូរកណ្ដៀរសែនជ័យ | 5 | 3 | 5.26 | 26.47 | 31.73 |
| សរុប | | | | 46 | 41 | 40.80 | 232.58 | 273.38 |

<u>សំគាល់</u>÷ រដ្ឋបាលឃុំ សង្កាត់ បង្កើតថ្មីទាំង០៦ អាចប្រើថវិកាផ្នែករដ្ឋបាលដែលផ្ដល់ជូនក្នុងឆ្នាំ២០២២នេះ ក្នុងជំពូក៦០ គណនី៦០០២ អនុគណនី៦០០២១ សម្ភារការិយាល័យតែប៉ុណ្ណោះ។

១/១

តារាងឧបសម្ព័ន្ធទី២ភ្ជាប់តាមសារាចរណែនាំលេខ ០០៩ សហវ ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០២២

ឯកតា: លានរៀល

| តារាងទិន្នន័យប្រាក់ឧបត្ថម្ភជូនភូមិបង្កើតថ្មីក្នុងខេត្តកំពង់ចាម ចាប់ពីខែមីនា ដល់ខែធ្នូ ឆ្នាំ២០២២ | | | | | |
|---|---|---|---|---|---|
| លេខកូដ ឃុំ សង្កាត់ | ឃុំ សង្កាត់ | ភូមិ | ប្រាក់ឧបត្ថម្ភ មន្ត្រីភូមិ | ប្រាក់ឧបត្ថម្ភ ចូលឆ្នាំ និងភ្ជុំ | សរុបប្រាក់ ឧបត្ថម្ភ |
| 03 | កំពង់ចាម | | | | |
| 0302 | ស្រុកចំការលើ | | | | |
| 030201 | បុសខ្នុរ | ភូមិចាំង១ | 10.20 | 0.30 | 10.50 |
| | | ភូមិចាំង២ | 10.20 | 0.30 | 10.50 |
| | | ភូមិបុសខ្នុរលើ | 10.20 | 0.30 | 10.50 |
| | | ភូមិ១០មករាលើ | 10.20 | 0.30 | 10.50 |
| 030203 | ជយោ | ភូមិជយោត្បូង | 10.20 | 0.30 | 10.50 |
| | | ភូមិអកមោក | 10.20 | 0.30 | 10.50 |
| 030206 | ស្វាយទាប | ភូមិថ្នល់បែកជើង | 10.20 | 0.30 | 10.50 |
| | | ភូមិថ្នល់បត់ | 10.20 | 0.30 | 10.50 |
| | | ភូមិបុស្សចេកព្រៃ | 10.20 | 0.30 | 10.50 |
| 030208 | តាប្រុក | ភូមិតាប៉ាង១ | 10.20 | 0.30 | 10.50 |
| | | ភូមិតាប៉ាង២ | 10.20 | 0.30 | 10.50 |
| | | ភូមិតាប៉ាង៣ | 10.20 | 0.30 | 10.50 |
| | | ភូមិតាប៉ាង៤ | 10.20 | 0.30 | 10.50 |
| សរុប | | | 132.6 | 3.90 | 136.50 |